NEW SOUTH WALES
DEPARTMENT
OF EDUCATION
AND TRAINING

# អានជាមួយកូនរបស់លោកអ្នកនៅផ្ទះ

## គំនិតខ្លះៗសំរាប់មាតាបិតា និងអ្នកមើលថែទាំកុមារតូចៗ

READING WITH YOUR CHILD AT HOME – IDEAS FOR PARENTS OF YOUNG CHILDREN

### ការអានគឺមានសារៈសំខាន់

READING IS IMPORTANT

- ការអានគឺជាជំនាញការសំខាន់ដែលតែងតែមានជានិច្ច ។ នៅក្នុងពិភពសម័យថ្មីរបស់យើងនេះ ការអានគឺរឹតតែមានសារៈសំខាន់ជាងពេលណាទាំងអស់។
- កុមាររៀនអំពីសារៈសំខាន់នៃការអាន នៅពេលគេឃើញសមាជិកនៃក្រុមគ្រួសាររបស់ខ្លួនប្រើការអាន និងការសរសេរសំរាប់គោលបំណងប្រចាំថ្ងៃជាច្រើន។
- ការអានជាមួយកូនរបស់លោកអ្នកនៅផ្ទះ នឹងជួយទៅកូនរបស់លោកអ្នកនៅគ្រប់ផ្នែកសិក្សាទាំងអស់នៅសាលារៀន។
- កុមារឃើញលោកអ្នកអាន និងសរសេរនៅក្នុងការរស់នៅប្រចាំថ្ងៃ ការអានសំរាប់ជាការកំសាន្ត ការប្រើរូបមន្តធ្វើម្ហូប ការធ្វើបញ្ជីទិញឥវ៉ាន់ ការសរសេរកាតខួបកំណើត ឬការអានផ្លាកសញ្ញានៅតាមផ្លូវថ្នល់។ លោកអ្នកអាចបង្រៀនកូនរបស់លោកអ្នកនៅក្នុងការអាននេះ ចំណែកឯការសរសេរវិញគឺជាជំនាញការដ៏សំខាន់នៅក្នុងការរស់នៅសព្វថ្ងៃនេះ។
- ជាញឹកញយ សាលារៀនតែងស្នើសុំឲ្យមាតាបិតាស្តាប់កូនរបស់ខ្លួនអាននៅផ្ទះ។ នេះគឺជាវិធីមួយដ៏ល្អនៃការជួយផ្គត់ផ្គង់ទៅដល់ការអានរបស់កូនលោកអ្នក។ លោកអ្នកអាចខ្ចីសៀវភៅពីបណ្ណាល័យសាលារៀន ឬពីបណ្ណាល័យប្រចាំតំបន់របស់លោកអ្នក។
- ត្រូវឲ្យមានការទុកចិត្តថាកូនរបស់លោកអ្នកនឹងចេះរៀនអាន។

### អ្វីដែលលោកអ្នកអាចជួយបាននៅផ្ទះ

WHAT YOU CAN DO AT HOME TO HELP

- ធ្វើជាខ្លួនរបស់លោកអ្នកផ្ទាល់។ ចូលរួមជាមួយកុមារនៅក្នុងការសន្ទនាប្រចាំថ្ងៃ។
- ការអានសម្លេងខ្លាំងៗឲ្យកុមារស្តាប់នឹងជួយឲ្យគេចេះអានរៀនភាសានៅក្នុងសៀវភៅ និងជួយលើកទឹកចិត្តគេឲ្យចូលចិត្តសៀវភៅ និងអានសៀវភៅផងដែរ។
- និយាយអំពីសៀវភៅ អានជាមួយគ្នា ហើយឲ្យការអានជាពេលមួយដ៏ជាទីរីករាយ និងធ្វើសកម្មភាពរួមគ្នា។
- ចូរឲ្យប្រាកដថាលោកអ្នកមានសម្ភារៈសំរាប់អានច្រើនបែបសំរាប់កូនរបស់លោកអ្នកនៅផ្ទះ គឺសៀវភៅរឿងប្រឌិត និងសៀវភៅរឿងពិត។

- នេះគឺជាការសំខាន់ដែលត្រូវអានឲ្យកូនរបស់លោកអ្នកស្តាប់នៅក្នុងភាសាដើមរបស់លោកអ្នក ប្រសិនបើភាសាទីមួយមិនមែនជាភាសាអង់គ្លេស។ ការពិសោធបង្ហាញឲ្យឃើញថា ការប្រើភាសាដើមរបស់លោកអ្នកនឹងជួយកូនរបស់លោកអ្នកឲ្យចេះអានភាសាអង់គ្លេស។
- សាកល្បងកុំឲ្យទូរទស្សន៍ជ្រែតជ្រែកនៅក្នុងពេលអាន។ ឲ្យមានពេលពិសេសសំរាប់ការអានជាមួយកូនរបស់លោកអ្នក ហើយត្រូវនៅឲ្យឆ្ងាយពីការរំខានទាំងឡាយ។
- ស្តាប់កូនរបស់លោកអ្នកអានឲ្យបានរៀងរាល់ថ្ងៃ ទោះបីជាក្នុងរយៈពេលខ្លីក៏ដោយ។
- ឲ្យសៀវភៅទៅកូនរបស់លោកអ្នក ទុកដូចជាការលើកទឹកចិត្ត ឬអំណោយ។

## គន្លឹះជំនួយខ្លះៗសំរាប់ការស្តាប់កូនរបស់លោកអ្នកអាន
### HINTS FOR LISTENING TO YOUR CHILD READ

- មុនពេលអាន ចូរនិយាយអំពីគម្របសៀវភៅ ចំណងជើង រួបភាពរួចពិភាក្សាអំពីអ្វីដែលមាននៅក្នុងសៀវភៅនោះ។
- ពេលកំពុងអាន ចូរពិភាក្សាអំពីសាច់រឿងទល់នឹងពេលអាន រួចសាកស្មានអំពីអ្វីដែលអាចកើតមានបន្ទាប់មកទៀត។
- ក្រោយពីអានរួចចូរនិយាយ ហើយសួរសំណួរអំពីសាច់រឿង និងរូបភាព។
- ពេលអានសៀវភៅដែលពិបាកជាមួយគ្នា ត្រូវឆ្លាស់វេនគ្នាអាន។ អ្នកដែលរៀនអានដំបូងអាចអានផ្នែកខ្លះដដែលៗ ហើយអ្នកដែលមានជំនាញច្រើនក្នុងការអាន អាចអានមួយឃ្លា ឬមួយទំព័រ។
- នៅពេលគិតរកពាក្យដែលមិនធ្លាប់ស្គាល់:

  **បង្អង់** ដើម្បីឲ្យកូនរបស់លោកអ្នកមានពេលដើម្បីគិតរកមើលពាក្យនោះ។

  **ឈប់ភ្លាមៗ**

  - ត្រឡប់ទៅដើមឃ្លាវិញ ឬអានឲ្យផុតពាក្យដែលពិបាកទៅដល់ចុងឃ្លានោះ
  - រកមើលគន្លឹះចម្លើយនៅក្នុងរូបភាព ឬក្នុងពាក្យ
  - មើលតួរអក្សរដំបូង រួចរកមើលថាតើវាទៅជាពាក្យអ្វី
  - សួរថា "តើវាមានន័យឬទេ?"
  - សាកល្បងបញ្ចេញជាសម្លេងពាក្យនោះ
  - ប្រសិនបើចាំបាច់ចូរនិយាយប្រាប់ពាក្យនោះទៅកូនរបស់លោកអ្នក

**លើកសរសើរ**កូនរបស់លោកអ្នកចំពោះការខិតខំរបស់គេ ទោះបីជាគេធ្វើខុសក្តី។

## អ្វីដែលត្រូវអាន និងធ្វើ
### WHAT TO READ AND DO

- និទានរឿង និងនិទានរឿងគ្រប់បែបម្តងទៀត រាប់បញ្ចូលទាំងរឿងដែលគេចូលចិត្ត រឿងព្រេង ដំណើរខ្សែភាពយន្តពិតមានក្នុងតំបន់ និងប្រវត្តិគ្រួសារ។
- លេងល្បែងខ្លះៗ ដូចជា "ខ្ញុំឃើញអ្វីមួយចាប់ផ្តើមជាមួយពាក្យ 'd' "

- ស្នើសុំឲ្យកូនរបស់លោកអ្នកអានរូបមន្តធ្វើម្ហូបងាយស្រួលណាមួយ នៅពេលលោកអ្នកកំពុងដាំស្ល។
- អានសៀវភៅរឿងមានរូបភាព ទស្សនាវដ្តី រឿងខ្លីៗ កំណាព្យ និងពាក្យចួនគ្នា រាប់បញ្ចូលទាំងកំណាព្យសំរាប់កុមារ។
- លេងល្បែងដាក់ពាក្យផ្គុំគ្នា និងល្បែងដោះស្រាយពាក្យឯទៀតជាមួយគ្នា។
- មើលកម្មវិធីទូរទស្សន៍ មុននឹងមើលទូរទស្សន៍។
- មើលក្រដាសដែលដាក់នៅក្នុងប្រអប់សំបុត្រជាមួយគ្នា។
- អានទិសដៅ និងសញ្ញានៅពេលបើកបរ និងទៅផ្សារ។
- អាន និងសរសេរកំណត់ខ្លីៗ និងសំបុត្រផ្ញើទៅគ្រួសារ។
- លេងល្បែងលើក្តារជាមួយគ្នា រួចអានក្បួនល្បែងនោះ។
- ឲ្យតួរអក្សរធ្វើពីផ្លាស្ទិក ខ្មៅដៃពណ៌ ខ្មៅដៃ ប៊ិច និងក្រដាសសរសេរ។

## ហើយចូរចងចាំ........

### AND DO REMEMBER . . .

- ពិភាក្សាអំពីន័យនៃសាច់រឿង និងពាក្យ។
- លើកទឹកចិត្តកូនរបស់លោកអ្នកឲ្យអានគ្រប់ទីកន្លែង នៅពេលណាក៏ដោយ។
- ឲ្យកូនរបស់លោកអ្នកដឹងថាលោកអ្នកពេញចិត្តក្នុងការអាន។
- ទៅលេង និងប្រើបណ្ណាល័យដែលនៅក្បែរលោកអ្នក។ ខ្ចីសៀវភៅសំរាប់លោកអ្នក និងសំរាប់កូនរបស់លោកអ្នកផងដែរ។
- និយាយទៅកាន់គ្រូបង្រៀនប្រចាំថ្នាក់របស់កូនលោកអ្នក ឬចាងហ្វាងសាលារៀនដើម្បីទទួលយកជំនួយ ឬឱវាទបន្ថែមទៀត។
- ចូរមានអំណរក្នុងការអាន ដ្បិតអីវាជាទីរីករាយ។

**ចូរទាក់ទងជាមួយនឹងសាលាប្រចាំតំបន់របស់លោកអ្នក ដើម្បីទទួលយកពត៌មានបន្ថែមទៀតស្តីអំពីរបៀបយ៉ាងណាដែលលោកអ្នកអាចជួយក្នុងការអានរបស់កូនលោកអ្នក។**